**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៧៧

ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៤

សាលដីកា

លេខ : ៤៧

ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៤

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០០៤ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធាន

២- លោក ឈឹម ស៊ីផល ជាចៅក្រម

៣- លោក រឿល មួន ជាចៅក្រម

៤- លោក ជីវ កេង ជាចៅក្រម

៥- លោក ប៉ែន សារឿន ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**

លោក សាន សុជាត

**តំណាងមហាអយ្យការ**

ឯកឧត្តម ជួន ស៊ុនឡេង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៣០"ឈ" ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣. លេខ០៧"ឈ" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៧៧ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

*__ពិបទ__* : ភេរវកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ តាមមាត្រា២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើភេរវកម្ម ។

១-ជនជាប់ចោទឈ្មោះអៀង យូ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ របររកស៊ីសិស្ស ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះលេខ៤០៨E₀ ផ្លូវ១២៨ ក្រុម៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា ក្រុងភ្នំពេញ ឪពុកឈ្មោះប៊ុន ខេង "រ" ម្តាយឈ្មោះ រួច ឆេង "រ" នៅលីវ ។ ក្រៅឃុំ ។

-មានមេធាវី អ្នកស្រី ពឹង ធីតា

២-ជនជាប់ចោទឈ្មោះគាង ផេង (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ទាហ្វៃ ទីលំនៅមុនថ្ងៃចាប់ខ្លួន ផ្ទះលេខ២៤៦ ផ្លូវ១៣២ ក្រុម២១ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ លី ឈុន "រ" ម្តាយឈ្មោះ គុយ ហៀង នៅលីវ ។ ក្នុងឃុំ ។

-មានមេធាវី លោក កែត ឃី

-ដើមបណ្តឹងរដ្ឋប្បវេណីលោកឃុន ម៉េង (ជាម្ចាស់បណ្តឹងសាទុក្ខ) ផ្ទេរសិទ្ធិឱ្យលោកឡាំង គឹមសេង ជាមេធាវីមានការិយាល័យផ្ទះលេខ៣៨១ មហាវិថីម៉ៅសេងទុង សង្កាត់ផ្សារដេប៉ូ២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

-ឯកឧត្តម អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ (ជាម្ចាស់បណ្តឹងសាទុក្ខ) ។

កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ មានអំពើចាប់ជំរិតទារប្រាក់បានសំរេច ហើយបានសំលាប់ជនរងគ្រោះចោល ដើម្បីបំបាត់ភស្តុតាងផ្សេងទៀត។ លុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ជនជាប់ចោទឈ្មោះគាង ផេង បានចេញមកសារភាពនៅស្នងការនគរបាលក្រុងភ្នំពេញ ដោយបានបញ្ជាក់ថា ពួកគេមានគ្នា៥នាក់ ដែលបាននាំគ្នាដើរលេងស៊ីផឹក ដោយបានជួលរថយន្ត០១គ្រឿង ដែលមានម៉ាក Camry សេរី៩១ ពួកគេបានសំលាប់ជនរងគ្រោះឈ្មោះឃុន ប៊ុនវេង ជំរិតយកប្រាក់បានសំរេចចំនួន២០.០០០ដុល្លា ហើយយកជនរងគ្រោះទៅសំលាប់ចោលទៀតផង ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការក្រុងភ្នំពេញថា : ចោទប្រកាន់លើឈ្មោះអៀង យូ ,គាង ផេង ពិតជាបានប្រព្រឹត្តអំពើភេរវកម្ម ជំរិតទារប្រាក់សំលាប់ជនរងគ្រោះឈ្មោះឃុន ប៊ុនវេង កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ នៅក្រុងភ្នំពេញប្រាកដមែន តាមបញ្ញត្តិមាត្រា២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើភេរវកម្ម ។

-បានឃើញសាលក្រមកំបាំងមុខព្រហ្មទណ្ឌលេខ១៥"ញ" ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១-ក/ផ្តន្ទាទោសឈ្មោះអៀង យូ ដាក់ពន្ធនាគារអស់១ជីវិត គិតពីថ្ងៃចាប់ខ្លួនបាន តាមអំណាចសាលក្រមចូលជាស្ថាពរ ។

ខ/ផ្តន្ទាទោសឈ្មោះគាង ផេង "ហ" ទី ដាក់ពន្ធនាគារចំនួន១៥ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៣ ។

ពីបទ : ភេរវកម្ម ប្រព្រឹត្តិនៅក្រុងភ្នំពេញកាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ បទល្មើសដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២ ច្បាប់ស្តីពីការបង្ក្រាបអំពើភេរវកម្ម និង មាត្រា៦៨ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ក/បង្គាប់អោយឈ្មោះប៊ុន ខេង រួច ឆេង ,អៀង យូ ,លី ឈុន"ហ"កែប លីឈុន គុយ ហៀង"ហ"គុយ អេង និង ឈ្មោះគាង ផេង"ហ"ទី រួមគ្នាសងប្រាក់១៩.១០០ដុល្លា ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឃុន ម៉េង វិញ ។

ខ/បង្គាប់អោយឈ្មោះប៊ុន ខេង រួច ឆេង ,អៀង យូ សងការខូចខាត និង ជំងឺចិត្តជាប្រាក់ចំនួន៧០០.០០០ដុល្លា ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឃុន ម៉េង ។

គ/បង្គាប់អោយឈ្មោះលី ឈុន"ហៅ"កែប លីឈុន .គុយ ហៀង"ហៅ"គុយ អេង និង ឈ្មោះគាង ផេង"ហៅ"ទី សងការខូចខាត និងជំងឺចិត្តជាប្រាក់ចំនួន៥០.០០០ដុល្លា ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឃុន ម៉េង ។ សំណូមពរលើសពីនេះ សំរេចបដិសេធចោល ។

ឃ/ក្នុងករណីទណ្ឌិត អៀង យូ .គាង ផេង មិនព្រមសងប្រាក់ សំរេចដាក់គុកបង្ខំរូបកាយដើម្បីទារប្រាក់ក្នុងរឿងព្រហ្មទណ្ឌ ។

៣-វត្ថុតាងមានទឹកប្រាក់ចំនួន២.៩០០ដុល្លា សំរេចឱ្យឈ្មោះគាង គុង ត្រូវជាបងបង្កើតគាង ផេង ប្រគល់ប្រាក់ចំនួន២.៩០០ដុល្លា នេះ ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឃុន ម៉េង វិញ ។

៤-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៣ លើកយកមកជំនុំជំរះបន្តនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ហើយប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ ចំពោះមុខជនជាប់ចោទឈ្មោះគាង ផេង កំបាំងមុខជនជាប់ចោទឈ្មោះអៀង យូ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី និង ប្រកាសជាសាធារណៈចំពោះមុខលោកស្រីមេធាវី ពីង ធីតាការពារឱ្យជនជាប់ចោទឈ្មោះអៀង យូ កំបាំងមុខលោកមេធាវី កែត ឃី ការពារឱ្យជនជាប់ចោទគាង ផេង សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ គិតពីថ្ងៃផុតបណ្តឹងទាស់ ។

-បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣របស់ឈ្មោះប៊ុន ខេង រួច ឆេង ប្តឹងមិនសុខចិត្តពីសាលក្រមកំបាំងមុខព្រហ្មទណ្ឌលេខ១៥"ញ" ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី២(ក.ខ) នៃសេចក្តីសំរេច ។

-បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៣ របស់ឈ្មោះកែប លីឈុន .គុយ អេង ប្តឹងមិនសុខចិត្តពីសាលក្រមកំបាំងមុខព្រហ្មទណ្ឌលេខ១៥"ញ" ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣របស់តុលាការក្រុងភ្នំពេញលើសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលក្រមព្រហ្មទណ្ឌកំបាំងមុខ ចាត់ទុកជាចំពោះមុខលេខ២៤"ញ" ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញដែលបានសំរេច :

១-ទទួលបណ្តឹងទាស់របស់ឈ្មោះប៊ុន ខេង និង រួច ឆេង ចុះថ្ងៃទី២៦ ខែមីនាឆ្នាំ២០០៣ និងបណ្តឹងទាស់របស់ឈ្មោះកែប លីឈុន និងនាងគុយ អេង ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៣ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និង លិខិតសុំពឹងពាក់មេធាវីលោក ឈរ លីថៃ ជាមេធាវីតំណាងរបស់ឈ្មោះប៊ុន ខេង និងនាងរួច ឆេង ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៣ និងចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៣ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ និង លិខិតសុំពឹងពាក់មេធាវីលោកកែត ឃី ជាមេធាវីរបស់ឈ្មោះកែប លីឈុន និង នាងគុយ អេង ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៣ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-កែតំរូវសាលក្រមព្រហ្មទណ្ឌលេខ១៥"ញ"ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី២(ក-ខ-គ) ដោយសំរេចជាថ្មីដូចតទៅ :

ក/បង្គាប់អោយឈ្មោះអៀង យូ ,គាង ផេង"ហ"ទី រួមគ្នាសងប្រាក់ចំនួន១៩.១០០ដុល្លា អោយទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះយុន ម៉េង វិញ ។

ខ/បង្គាប់ឱ្យឈ្មោះអៀង យូ សងការខូចខាត និង ជំងឺចិត្តចំនួន៧០០.០០០ដុល្លា ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះយុន ម៉េង ។

គ/បង្គាប់ឱ្យឈ្មោះគាង ផេង"ហ"ទី សងការខូចខាត និងជំងឺចិត្តជាប្រាក់ចំនួន ៥០.០០០$ ទៅអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះយុន ម៉េង។ សំណូមពរលើស សំរេចបដិសេធចោល ខ្លឹមសារផ្សេងក្រៅពីនេះរក្សាទុកតាមច្បាប់ដដែល ។

៥-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវី ការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១១"ញ" ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ របស់ឈ្មោះគាង ផេង ប្តឹងមិនសុខចិត្តពីសាលក្រមកំបាំងមុខព្រហ្មទណ្ឌលេខ១៥"ញ" ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៦"ញ"ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ របស់លោកព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ប្តឹងមិនសុខចិត្តពីសាលក្រមកំបាំងមុខព្រហ្មទណ្ឌលេខ១៥"ញ" ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ការផ្តន្ទាទោសជនជាប់ចោទឈ្មោះអៀង យូ ធ្ងន់ពេក ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៥"ញ"ស្ទួន ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ របស់អ្នកស្រីពីង ធីតា មេធាវីការពារឱ្យជនជាប់ចោទឈ្មោះអៀង យូ ប្តឹងមិនសុខចិត្តពីសាលក្រមកំបាំងមុខព្រហ្មទណ្ឌលេខ១៥"ញ"ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី១"ក"ទី២"ខ" នៃសេចក្តីសំរេច ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៥"ញ" ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ របស់ឈ្មោះយុន ម៉េង ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ២៤"ញ" ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញត្រង់ចំណុចទី៤ នៃសេចក្តីសំរេច ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៥"ញ" ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៣ របស់អ្នកស្រីពីង ធីតា មេធាវីការពារឱ្យជនជាប់ចោទឈ្មោះអៀង យូ ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ២៤"ញ" ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី២"ក,ខ" នៃសេចក្តីសំរេច។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ របស់ព្រះរាជអាជ្ញា ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ របស់ឃុន ម៉េង ,ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ របស់គាង ផេង និង ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ ,ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣របស់អ្នកស្រីពីង ធីតា មេធាវីការពារឱ្យជនជាប់ចោទឈ្មោះអៀង យូ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ២៤"ញ" ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ និង កែប្រែសាលក្រមលេខ១៥"ញ" ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញជាថ្មី ។

-បានឃើញសាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ៣០"ឈ"ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ របស់ព្រះរាជអាជ្ញា អម តុលាការក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ របស់លោកស្រីពីង ធីតា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះអៀង យូ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹង គតិច្បាប់ ។

៣-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ របស់ឈ្មោះឃុន ម៉េង ជាដើមបណ្ដឹងរដ្ឋប្បវេណី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

៤-ទុកជាមោឃៈសាលក្រមព្រហ្មទណ្ឌលេខ២៤"ញ"ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣របស់តុលាការក្រុងភ្នំពេញទាំងមូល ។

៥-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៥"ញ"ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ វៀរលែងរយៈពេលផ្តន្ទាទោសលើឈ្មោះគាង ផេង ចំណុចទី២(ក-ខ-គនិងឃ) ត្រូវកែប្រែជាថ្មី ។

ក/កែប្រែរយៈពេលផ្តន្ទាទោសលើឈ្មោះគាង ផេង ពីការដាក់ពន្ធនាគារចំនួន១៥ឆ្នាំ មក ១០ឆ្នាំវិញ តាមមាត្រា៦៨ ស្តីពីស្ថានសំរាលទោសច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ខ/បង្គាប់អោយឈ្មោះប៊ុន ខេង រួច ឆេង អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណីលើឈ្មោះ អៀង យូ និង គាង ផេង រួមគ្នាសងប្រាក់ជីវិតចំនួន១៩.១០០ដុល្លា និងសំណងជំងឺចិត្តចំនួន៧០០.០០០ដុល្លា ទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះឃុន ម៉េង ។ សំណូមពរលើសពីនេះ បដិសេធចោល ។

គ/ទុកសិទ្ធិឱ្យ ប៊ុន ខេង រួច ឆេង និង គាង ផេង ប្ដឹងទាមទារប្រាក់សំណងរដ្ឋប្បវេណី ពីឈ្មោះម៉ៅ សុខអួន ,ជិន សុភ័ក្រ ,យ៉ង់ វុត្ថា នូវចំណែកដែលខ្លួនបានចេញជួស ។

ឃ-ក/ក្នុងករណី ប៊ុន ខេង រួច ឆេង និង គាង ផេង គ្មានប្រាក់សង អនុញ្ញាតឱ្យរឹបអូស ទ្រព្យសម្បត្តិរបស់អ្នកទាំង២ លក់ឡាយឡុង ដើម្បីយកប្រាក់សងសំណងធនទណ្ឌ ។

ឃ-ខ/បើពុំគ្រប់អនុញ្ញាតឱ្យដាក់គុកបង្ខំលើរូបកាយលើឈ្មោះគាង ផេង តាមមាត្រា៧ ច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ។ ចំណុចផ្សេងពីនេះនៃសាលក្រមរក្សាទុកជាបានការដដែល ។

៦-ក្នុងករណីឈ្មោះគាង ផេង ពុំព្រមសងប្រាក់២.៨០០$ នេះ អនុញ្ញាតឱ្យរឹបអូសទ្រព្យសម្បត្តិរបស់ គាង ផេង លក់ឡាយឡុងយកប្រាក់សងទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

៧-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៣ ចំពោះមុខជនជាប់ចោទឈ្មោះគាង ផេង ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះយុន ម៉េង មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោកសែម ចិន្តា លោកឡាំង គីមសេង កំបាំងមុខជនជាប់ចោទឈ្មោះអៀង យូ អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណីអៀង យូ ប៊ុន ខេង រួច ឆេង មេធាវីការពារឱ្យអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណីលោកឈរ លីថៃ កំបាំងមុខឈ្មោះកែប លីឈុន ,គុយ អេង មេធាវី កែត ឃី លោកឈីវ ថេង និងលោកស្រី ពឹង ធីតា ប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣ចំពោះមុខលោកយុន ម៉េង លោកមេធាវីឡាំង គីមសេង កំបាំងមុខជនជាប់ចោទ អៀង យូ ,គាង ផេង អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណីឈ្មោះប៊ុន ខេង រួច ឆេង ,កែប លីឈុន គុយ អេង មេធាវីលោកកែត ឃី ,សែម ចិន្តា ,ឈីវ ថេង ,ពឹង ធីតា និង ឈរ លីថៃ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងទាស់លេខ៣០ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ របស់អ្នកស្រីពឹង ធីតា មេធាវីការពារឱ្យជនជាប់ចោទឈ្មោះអៀង យូ និង បណ្តឹងទាស់លេខ៣១ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ របស់លោកកែត ឃី មេធាវីការពារឱ្យអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណីឈ្មោះប៊ុន ខេង រួច ឆេង ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៣០"ឈ"ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌកំបាំងមុខ ចាត់ទុកជាចំពោះមុខលេខ០៧"ឈ" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងទាស់ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ របស់អ្នកស្រីមេធាវីពឹង ធីតា និង លោកកែត ឃី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ៣០"ឈ" ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ដោយគ្រាន់តែបដិសេធចំណុចទី៥"ខ ,គ ,ឃ្មនិងឃ២ នៃសេចក្តីសំរេចចោលជាអសារបង់ ។ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល ។

៣-កែប្រែរយៈពេលនៃការផ្តន្ទាទោសលើឈ្មោះអៀង យូ ក្នុងចំណុចទី១(ក) នៃសេចក្តីសំរេចរបស់សាលក្រមព្រហ្មទណ្ឌលេខ១៥"ញ" ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញពីរយៈពេលអស់១ជីវិត មកត្រឹម១៧ឆ្នាំវិញ ។

៤-ទុកសិទ្ធិអោយឈ្មោះប៊ុន ខេង ,រួច ឆេង ប្តឹងទាមទារចំណែកនៃប្រាក់សំណងរដ្ឋប្បវេណីពីជនជាប់ចោទ គាង ផេង ,ម៉ៅ សុខអ៊ូន ,ជិន សុភ័ក្រ និង យង់ វុត្ថា តាមច្បាប់ ។

៥-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៤ ចំពោះមុខមេធាវីការពារជនជាប់ចោទឈ្មោះអៀង យូ និង មេធាវីការពារឱ្យឈ្មោះប៊ុន ខេង ,រួច ឆេង កំបាំងមុខជន ជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី និង ប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៤ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងមេធាវីការពារអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី តែចាត់ទុកជាចំពោះមុខ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១១៣ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ឈ្មោះគាង ផេង ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៣០"ឈ"ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញបណ្តឹងសាទុក្ខលេខ៥៩ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៤ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ០៧"ឈ"ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចការផ្តន្ទាទោសជនជាប់ចោទឈ្មោះអៀង យូ ក្រោមអប្បបរិមានៃទោស ។

-បានឃើញបណ្តឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៤របស់ឈ្មោះឃុន ម៉េង ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ០៧"ឈ"ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ ,៣ និង ៤ នៃសេចក្តីសំរេច ។

-បានឃើញបណ្តឹងសាទុក្ខលេខ៣៥ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៤ របស់លោកស្រីពីង ធីតា មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ អៀង យូ ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ០៧"ឈ" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៤ របស់ អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណា និង សារណាតបចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤ របស់អ្នកស្រីមេធាវី ពីង ធីតា ការពារឱ្យជនជាប់ចោទ អៀង យូ (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណា និង សារណាតប ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ របស់ជនជាប់ចោទឈ្មោះគាង ផេង (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤ និង សារណាតបចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៤ របស់មេធាវីឡាំង គឹមសេង តំណាងផ្ទេរសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីលោកឃុន ម៉េង (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : មានភស្តុតាងគ្រប់គ្រាន់ ដើម្បីដាក់បន្ទុកលើឈ្មោះអៀង យូ រីឯការដាក់ទណ្ឌកម្មលើជនជាប់ចោទឈ្មោះអៀង យូ និងគាង ផេង ឃើញថា ត្រឹមត្រូវហើយ ម្យ៉ាងទៀតដោយដើមបណ្តឹងរដ្ឋប្បវេណីលោកឃុន ម៉េង សុំដកបណ្តឹងសាទុក្ខរបស់ខ្លួនវិញ សូមឱ្យតុលាការតម្កល់សាលដីកាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់អំណានសារណារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍(ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះគាង ផេង (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : មូលហេតុដែលខ្ញុំបាទប្តឹងមកនេះ ខ្ញុំមិនសុខចិត្តការដាក់ទណ្ឌកម្មខ្ញុំ១០ឆ្នាំ ព្រោះខ្ញុំបាទមិនបានចូលរួមប្រព្រឹត្តិបទល្មើសនេះ ខ្ញុំបានចេញមកសារភាពហើយ។ គេដាក់ទណ្ឌកម្មខ្ញុំទៀត ក្នុងស្ថានភាពនោះ គេបង្ខំខ្ញុំទេ។ ក្នុងចំណោមសំបុត្រសារភាពរបស់ខ្ញុំមានមួយត្រឹមត្រូវ ប៉ូលីសមិនបានបង្ខិតបង្ខំឱ្យខ្ញុំឆ្លើយទេ ។ សូមតុលាការលើកលែងទោសខ្ញុំផង ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកែត ឃី មេធាវីការពារឱ្យជនជាប់ចោទឈ្មោះគាង ផេង (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ថា : កូនក្តីខ្ញុំមិនបានទៅបបួលជនជាប់ចោទឯទៀតដើរលេងទេ ពួកគេជាអ្នកមកបបួលកូនក្តីខ្ញុំ ក្នុងរឿងនេះពុំមានធាតុផ្សំគ្រប់គ្រាន់ទេ។ កូនក្តីខ្ញុំមិនបានចាយលុយ២.៩០០$ លុយនេះ គាង ផេង បានប្រគល់ឱ្យប៉ូលីសអស់ហើយ កូនក្តីខ្ញុំជាមនុស្សស្លូតត្រង់ ហើយបានចេញមកសារភាពទៀត តាមច្បាប់ពុំមានទោសឡើយ សូមតុលាការលើកលែងទោស។ ណាមួយដើមបណ្តឹងរដ្ឋប្បវេណីលោកឃុន ម៉េង បានដកបណ្តឹងសាទុក្ខរបស់ខ្លួនវិញ សូមបញ្ចប់រឿងនេះទៅ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកស្រី ពឹង ធីតា មេធាវីការពារឱ្យជនជាប់ចោទឈ្មោះអៀង យូ (ជាម្ចាស់បណ្តឹងសាទុក្ខ)នៅពេលជំនុំជំរះថា : ឆ្លងតាមការសន្និដ្ឋានរបស់តំណាងមហាអយ្យការ មេធាវីរបស់ឈ្មោះគាង ផេង ថា ការចូលសារភាពនេះគ្មាន ការបង្ខិតបង្ខំទេ នេះជាការត្រឹមត្រូវ ប៉ុន្តែចំលើយសារភាពនេះមានការប្រែប្រួលរហូត ។ លុយ២.៩០០$ ពុំមែនជាលុយបានមកពីការចាប់ជីវិតទេ គឺជាលុយម្តាយគាង ផេង ។ នៅតុលាការក្រុងភ្នំពេញ នាងខ្ញុំសូមឱ្យចៅក្រមស៊ើបអង្កេត ស៊ើបអង្កេតលើឯកសារមួយចំនួនដូចជា:

-កិច្ចសន្យាជួលរថយន្ត ពុំមានស្នាមមេដៃម្ចាស់រថយន្ត

-ទូរសព្ទ ០១២

-សាវតាជាតិលើឈ្មោះគង់ ផន

ដូច្នេះ បើពុំធ្វើការស៊ើបអង្កេតលើឯកសារទាំងនេះទេ ពិតជាគ្មានភស្តុតាងដាក់បន្ទុកលើកូនក្តីនាងខ្ញុំឡើយ ។ សូមតុលាការលើកលែងចោទប្រកាន់ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឡាំង គឹមសេង តំណាងផ្ទេរសិទ្ធិឱ្យលោកឃុន ម៉េង (ជាម្ចាស់បណ្តឹងសារទុក្ខ) នៅពេលជំនុំជំរះថា : រឿងនេះ ដោយសារលោកឃុន ម៉េង ដក បណ្តឹងសាទុក្ខហើយ ខ្ញុំពុំចាំបាច់សេចក្តីសន្និដ្ឋានឱ្យស៊ីជំរៅទៀតទេ ចំពោះជនជាប់ចោទ ពិតជាមានភស្តុតាងគ្រប់គ្រាន់ សូមតុលាការអនុវត្តទណ្ឌកម្ម តាមសាលដីកាសាលាឧទ្ធរណ៍ដោយក្តីអនុគ្រោះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូលនៅពេលជំនុំជំរះថា : ចំពោះចំលើយសារភាពរបស់ គាង ផេង មានការប្រែប្រួលមែន តែនាពេលនេះ គាង ផេង បានឆ្លើយបញ្ជាក់យកចំលើយមួយដែលត្រឹមត្រូវ រីឯមេធាវី ពីង ធីតា សូមឱ្យស៊ើបអង្កេតលើកិច្ចសន្យាជួលរថយន្តនោះ គឺពុំចាំបាច់ទេ ព្រោះមានឈ្មោះជា ពៅ ជាម្ចាស់រថយន្តជួលនោះអាចបញ្ជាក់គ្រប់គ្រាន់ហើយ ។ សូមតុលាការតម្កល់សាលដីកាសាលាឧទ្ធរណ៍ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចំលើយជនជាប់ចោទឈ្មោះ គាង ផេង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទឈ្មោះ អៀង យូ ,គាង ផេង និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

<u>*តុលាការកំពូល*</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៥៩ ចុះថ្ងៃទី១០-៥-២០០៤ របស់អគ្គព្រះរាជអាជ្ញា អមសាលា-ឧទ្ធរណ៍ បណ្តឹងសាទុក្ខលេខ ៥៤ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៤ របស់ដើមបណ្តឹងរដ្ឋប្បវេណី បណ្តឹងសាទុក្ខលេខ៣៥ ចុះថ្ងៃទី២-៤-២០០៤ របស់មេធាវីជនជាប់ចោទឈ្មោះ អៀង យូ និងបណ្តឹងសាទុក្ខលេខ ១១៣ ចុះថ្ងៃទី៤-១១-២០០៣ របស់ជនជាប់ចោទឈ្មោះ គាង ផេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍សន្និដ្ឋាន សុំតម្កល់ទោសអស់មួយជីវិតលើជនជាប់ចោទឈ្មោះ អៀង យូ តាមសាលក្រមព្រហ្មទណ្ឌលេខ១៥ "ញ"ចុះថ្ងៃទី១៧-៣-២០០៣ របស់តុលាការក្រុងភ្នំពេញនោះ តុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះតាមមាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល តុលាការអាចបន្ថយទណ្ឌកម្មដល់ក្រោមអប្បបរិមា នៃទោសបានចំពោះអនីតិជន ។

-យល់ឃើញថា ការដែលអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍សន្និដ្ឋានថា: មុននឹងសំរេចសេចក្តីតុលាការគប្បីមានការអង្កេតរកឯកសារផ្សេងៗ បញ្ជាក់ ពិសេសត្រូវមានសាលក្រមបញ្ជាក់អំពីសំបុត្រកំណើតណាមួយត្រឹមត្រូវ ក្នុងចំណោមសំបុត្រកំណើតទាំងពីរនោះ តុលាការកំពូលយល់ថា ពុំចាំបាច់ទេ ពីព្រោះសំបុត្រកំណើតលេខ១២០ ចុះថ្ងៃទី៣-០១-២០០០ ចុះបញ្ជីលេខ២០៥/៩៧ ចុះថ្ងៃទី៥-៩-៩៧ ដែលឈ្មោះ

ប៊ុន ខេង ជាឪពុកជនជាប់ចោទបានប្រកាសនៅថ្ងៃទី០៥-៩-៩៧ ថាឈ្មោះអៀង យូ កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨២ គឺបានធ្វើមុន ហើយពុំទាន់មានសាលក្រមបដិសេធចោលនូវសំបុត្រកំណើតនេះទេ។ រីឯសំបុត្រកំណើតលេខ១២០៣០៦ ចុះបញ្ជីលេខ១០០៤/២០០២ ចុះថ្ងៃទី៣០-៧-២០០២ ដែលបញ្ជាក់ថា ឈ្មោះអៀង យូ កើតថ្ងៃទី៥-៧-៨០ គឺឈ្មោះអៀង យូ បានទៅចុះដោយផ្ទាល់ ក្រោយពេលដែលខ្លួនបានប្រព្រឹត្តបទល្មើសរួចហើយ ហើយក្នុងពេលដែលសំបុត្រកំណើតមុននៅមានសុពលភាពនៅឡើយនោះ ពុំអាចឱ្យតុលាការយកមកពិចារណាបានទេ ។

-យល់ឃើញថា លោកឡាំង គឹមសេង និងអ្នកស្រី សួងខាហ៊្គិច ជាភរិយាលោកឃុន ម៉េង បានប្តឹងសុំដកបណ្តឹងសាទុក្ខរបស់ខ្លួន ត្រង់ចំណុចទី៣ នៃសាលដីកាព្រហ្មទណ្ឌលេខ ០៧ "ឈ" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ដែលកែប្រែការផ្តន្ទាទោសឈ្មោះអៀង យូ ពី០១ជីវិតមក១៧ឆ្នាំ ហើយលោកឡាំង គឹមសេង និងលោកឃុន ម៉េង បានប្តឹងសុំដកបណ្តឹងសាទុក្ខតាមពាក្យចុះថ្ងៃទី០៤-១០-២០០៤ វិញហើយ ។ ដូច្នេះ តុលាការកំពូលគប្បីពិចារណា ។

-យល់ឃើញថា ការដែលជនជាប់ចោទឈ្មោះគាង ផេង លើកឡើងនៅក្នុងសារណាចុះថ្ងៃទី០១-៩-២០០៤ ថា បទល្មើសនេះ ពុំមានពាក់ព័ន្ធជាមួយខ្លួនទេ គឺគេបបួលខ្លួនដើរលេងនៅក្រុងតាខ្មៅ បើដឹងមុនថា ឈ្មោះ អៀង យូ មានគំនិតមិនល្អ ខ្លួនមិនដើរលេងជាមួយទេ ខ្លួនមិនបានចូលរួមប្រព្រឹត្តិទេ ហើយថាខ្លួនគ្មានចេតនាក្នុងចិត្តគឺគ្មានទោស នោះជាការពុំត្រឹមត្រូវទេ ពីព្រោះតាមចំលើយសារភាពរបស់ខ្លួនជនជាប់ចោទឈ្មោះគាង ផេង ពិតជាបានទទួលផែនការនៅយាមជនរងគ្រោះ ក្នុងបន្ទប់សណ្ឋាគារ យាមឡានជិះឡានជាមួយជនរងគ្រោះ ពីសណ្ឋាគារយកជនរងគ្រោះទៅចោលនៅវត្តសន្សំកុសលនិងបានទទួលប្រាក់ ដែលបានមកពីផលនៃអំពើចាប់ជីវិតនេះប្រាកដមែន ។ ដូច្នេះ បើឈ្មោះគាង ផេង ពុំមែនជាអ្នកផ្តើមគំនិតក៏ជាអ្នកចូលរួមប្រព្រឹត្តិដែរ ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទឈ្មោះអៀង យូ លើកឡើងក្នុងសារណាចុះថ្ងៃទី ២៣-៨-២០០៤ ថា ចៅក្រមស៊ើបអង្កេតមិនទាន់បានធ្វើការស៊ើបអង្កេតឱ្យអស់ទេ ដូចជាមិនទាន់ធ្វើកោសល្យវិច្ច័យលើស្នាមមេដៃក្នុងកិច្ចសន្យាជួលឡាន ចុះថ្ងៃទី១០-៦-៩៩ មិនទាន់រកឯកសារពាក់ព័ន្ធ នឹងការប្រើប្រាស់ប្រព័ន្ធទូរស័ព្ទលេខ០១២ និងមិនទាន់បានស្រាវជ្រាវរកសាវតាជាតិជនល្មើសម្នាក់ទៀត ឈ្មោះគង់ ផននោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា ឈ្មោះជា ពៅ ជាម្ចាស់រថយន្តបានបញ្ជាក់ច្បាស់ហើយថា អ្នកទៅជួលធ្វើកិច្ចសន្យាជួល និងអ្នកបើករថយន្ត គឺជាឈ្មោះ ប៊ុន អៀងយូ (ហ) អៀង យូ នេះឯង ម្តាយជនរងគ្រោះក៏ឆ្លើយពីភិនភាគឡានស៊ីសង្វាក់គ្នាដែរ ហើយចំលើយជនជាប់ចោទឈ្មោះគាង ផេង បានបញ្ជាក់ច្បាស់ថាលេខទូរស័ព្ទ០១២ ៨៨៥ ៦៨៦ ជាលេខទូរស័ព្ទរបស់ឈ្មោះអៀង យូ ឯលេខ ០១២ ៨៥១ ៩៧៤ ជាលេខរបស់អាយ៉ង ។ បើវាមិនមែនជាកម្មសិទ្ធិរបស់ឈ្មោះអៀងយូ ក៏ឈ្មោះនេះជាអ្នកប្រើមុនពេល និងក្នុងពេល

ប្រព្រឹត្តបទល្មើសដែរ ។ ម្យ៉ាងទៀតតាមចំលើយរបស់ គាង ផេង មុនពេលប្រព្រឹត្តបទល្មើស និង ក្នុងពេលប្រព្រឹត្តបទល្មើស ពុំមានឈ្មោះគង់ ផន ចូលរួមទេ ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទឈ្មោះអៀង យូ លើកឡើងក្នុងសារណាថា ពុំមានភស្តុតាងណាដាក់បន្ទុកលើឈ្មោះអៀងយូ ក្រៅពីចម្លើយរបស់ឈ្មោះគាង ផេងនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា មានភស្តុតាងជាច្រើនទៀត ស៊ីសង្វាក់គ្នា ដែលបញ្ជាក់ថា ជនជាប់ចោទឈ្មោះអៀងយូ ពិតជាបានប្រព្រឹត្តិបទល្មើសដូចការចោទប្រកាន់មែន ដូចជាឈ្មោះជា ពៅ បញ្ជាក់ថា ឈ្មោះអៀង យូ បានមកជួលឡានខ្លួនពណ៌ក្រហម ជនរងគ្រោះប្រាប់ម្តាយខ្លួនថា ឈ្មោះអៀង យូ បានបបួលខ្លួនទៅដើរលេង ម្តាយជនរងគ្រោះឃើញជនរងគ្រោះឡើងជិះឡានពណ៌ក្រហមជាមួយឈ្មោះអៀង យូ ហើយតាមការឆែកពិនិត្យមើលលេខទូរស័ព្ទ គឺមានលេខទូរស័ព្ទដែលឈ្មោះអៀង យូ ប្រើបានហៅចូលទៅលេខជនរងគ្រោះជាច្រើនដងទៀត ដែលគ្រួសារជនរងគ្រោះស្គាល់លេខទូរស័ព្ទ និងសំលេងឈ្មោះអៀង យូ ច្បាស់ ពីព្រោះគ្រួសារទាំង២នេះធ្លាប់ស្គាល់គ្នាពីមុនមកច្បាស់លាស់ណាស់។ ម្យ៉ាងទៀតឈ្មោះអៀង យូ ក៏បានសារភាពថា បានជិះឡានមកដេកនៅសណ្ឋាគារកន្លែងកើតហេតុមែន។ ដោយឡែកគ្រួសារជនរងគ្រោះបានបញ្ជាក់គួរឱ្យជឿបានថា ឈ្មោះអៀង យូ បានព្យាយាមបបួលកូនខ្លួនជាច្រើនដងទៅដើរលេង ដោយសារតែស្គាល់ឈ្មោះ អៀង យូ ច្បាស់ទើបខ្លួនអនុញ្ញាតឱ្យកូនទៅដើរលេង បើក្រៅពីឈ្មោះអៀង យូ ខ្លួនប្រាកដជាមិនឱ្យទៅទេ ពីព្រោះជនជាប់ចោទផ្សេងទៀតខ្លួនមិនស្គាល់ ។ ភស្តុតាងទាំងនេះ គឺស៊ីសង្វាក់គ្នាជាមួយនឹងចំលើយជនជាប់ចោទឈ្មោះគាង ផេង ដែរ អាចឱ្យតុលាការ ជឿបាន ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទឈ្មោះអៀង យូ ធ្វើសេចក្តីសន្និដ្ឋាននៅពេលសវនាការនេះ ពុំមានភស្តុតាងណាដោះបន្ទុក ឬ ភស្តុតាងផ្ទុយដើម្បីដោះបន្ទុកឱ្យជនជាប់ចោទឈ្មោះអៀងយូរួចខ្លួនពីបទចោទប្រកាន់បានទេ ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទឈ្មោះអៀងយូ លើកឡើងថា លិខិតសារភាពរបស់ឈ្មោះគាង ផេង ចុះថ្ងៃខែតែមួយ ប៉ុន្តែមានខ្លឹមសារ២ផ្ទុយគ្នា ពុំអាចយកជាការបាននោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះឈ្មោះគាង ផេង បានបញ្ជាក់ថា នៅលើលិខិតសារភាពទាំង២នោះថា មួយជាលិខិតសារភាពដោយពិតប្រាកដ ឯឯកសារមួយទៀត ជាឯកសារសារភាព ដែលគេហៅឱ្យសរសេរតាម។ នៅពេលសវនាការនេះ ជនជាប់ចោទឈ្មោះគាង ផេង ក៏បានឆ្លើយសារភាពដូចគ្នានឹងចម្លើយសារភាពពិតប្រាកដរបស់ខ្លួននៅស្នងការប៉ូលីសដែរ ។

-យល់ឃើញថា ជនជាប់ចោទឈ្មោះអៀង យូ ដើមបណ្តឹងរដ្ឋប្បវេណី ពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម។ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៧"ឈ"ចុះថ្ងៃទី១៦-៣-២០០៤របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

***ហេតុដូច្នេះ***

***វិនិច្ឆ័យសេចក្ដីចំពោះមុខជនជាប់ចោទឈ្មោះគាង ផេង កំបាំងមុខជនជាប់ចោទ***

***ឈ្មោះអៀងយូ និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ឃុន ម៉េង ប៉ុន្តែចាត់ទុកជាចំពោះមុខ :***

១-ទទួលបណ្ដឹងសាទុក្ខលេខ៥៩ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៤ របស់អគ្គព្រះរាជអាជ្ញា អម សាលាឧទ្ធរណ៍ បណ្ដឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី២៦-៤-២០០៤ របស់ដើមបណ្ដឹងរដ្ឋប្បវេណី បណ្ដឹងសាទុក្ខ លេខ៣៥ ចុះថ្ងៃទី២-៤-២០០៤ របស់មេធាវីជនជាប់ចោទឈ្មោះអៀងយូ និង បណ្ដឹងសាទុក្ខលេខ១១៣ ចុះថ្ងៃទី៤-១១-២០០៣ របស់ជនជាប់ចោទឈ្មោះគាង ផេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធ ចោលដោយខុសនឹងគតិច្បាប់ ។

២-ទទួលពាក្យសុំដកបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី៩-៨-២០០៤ និងចុះថ្ងៃ ទី០៤-១០-២០០៤ ដែលប្ដឹងសុំដកបណ្ដឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី២៦-៤-២០០៤ របស់ខ្លួនវិញ ទុកជា ត្រឹមត្រូវតាមច្បាប់ ។

៣-អនុញ្ញាតឱ្យដើមបណ្ដឹងរដ្ឋប្បវេណីដកបណ្ដឹងសាទុក្ខតាមសុំ ។

៤-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៧ "ឈ" ចុះថ្ងៃទី១៦-៣-២០០៤ របស់សាលាឧទ្ធរណ៍ ទុក ជាបានការពេញទាំងមូល ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៤ ។